ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * *

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
* * * * * *

## អាមេរិកអះអាងពីគោលបំណងរក្សាការសន្ទនា និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា

* * * * * *

ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជួបគណៈប្រតិភូរបស់សភាសហរដ្ឋអាមេរិក ដឹកនាំដោយឯកឧត្តម Rodney Frelinghuysen ប្រធានគណៈកម្មាធិការគ្រប់គ្រងនិងបែងចែកថវិកាជាតិនៃរដ្ឋសភាអាមេរិក (US House Committee on Appropriations) នៅរសៀលថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៨។ ការពិភាក្សាបានផ្តោតជាសំខាន់ទៅលើទំនាក់ទំនងកម្ពុជា-អាមេរិក ហើយនិងកិច្ចសហប្រតិបត្តិការទ្វេភាគី លើការបញ្ជូនពលរដ្ឋខ្មែរមកកម្ពុជាវិញ និងការស្វែងរកអដ្ឋិធាតុទាហានអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម (MIA)។

លើទំនាក់ទំនងកម្ពុជា-អាមេរិក **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ និងបានគូសបញ្ជាក់ពីបំណងប្រាថ្នារបស់**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ចង់ឲ្យមានទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អ ជាមួយគ្រប់ប្រទេស រាប់ទាំងសហរដ្ឋអាមេរិក។ ក្នុងន័យនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងពីការជួបប្រាស្រ័យជាបន្តបន្ទាប់ជាមួយមន្ត្រីជាន់ខ្ពស់ជាច្រើនរបស់ក្រសួងការបរទេស ក្រសួងសន្តិសុខមាតុភូមិ សេតវិមាន ហើយនិងឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ពិភាក្សាផ្លាស់ប្តូរយោបល់លើការកែលំអទំនាក់ទំនងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរលើវិស័យមួយចំនួន ពិសេសការប្រឆាំងភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការរក្សាសន្តិភាពពិភពលោកក្រោមឆ័ត្ររបស់អង្គការសហប្រជាជាតិ កិច្ចសហប្រតិបត្តិការលើការស្វែងរកអដ្ឋិធាតុទាហានអាមេរិកដែលបានបាត់ខ្លួននៅកម្ពុជា (MIA) និងកិច្ចសហប្រតិបត្តិការលើការបោសសំអាតមីន ហើយ**ឯកឧត្តម** ក៏បានសម្តែងអំណរគុណចំពោះសហរដ្ឋអាមេរិកដែលបានសម្រេចបន្តជំនួយដល់ការបោសសំអាតមីនសម្រាប់រយៈពេលពីរឆ្នាំទៅមុខទៀត។

ឯកឧត្តម Rodney Frelinghuysen បានគូសបញ្ជាក់ពីគោលបំណងរបស់គណៈប្រតិភូ សំដៅរក្សាការទាក់ទង និងការសន្ទនាជាមួយកម្ពុជា ការបន្តកិច្ចសហប្រតិបត្តិការដែលប្រទេសទាំងពីរបានឯកភាពគ្នា និងបានអះអាងពីការវាយតម្លៃខ្ពស់របស់សភាសហរដ្ឋអាមេរិកចំពោះសារៈសំខាន់នៃទំនាក់ទំនងរវាងអាមេរិកជាមួយកម្ពុជា។ **ឯកឧត្តម** ក៏បានលើកឡើងអំពីបំណងរបស់អាមេរិកក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា លើបណ្តាវិស័យផ្សេងៗទៀត ដូចជាផ្នែកយោធា និងសកម្មភាពបោសសំអាតមីននៅកម្ពុជា។

ចំពោះការបញ្ជូនពលរដ្ឋខ្មែរមកកម្ពុជាវិញ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់យ៉ាងច្បាស់អំពីសុឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទទួលយកពលរដ្ឋខ្មែរដែលអាមេរិកសម្រេចបញ្ជូនមកកម្ពុជាវិញ និងបានលើកឡើងពីភាពមិនសមស្របនៃការសម្រេចរបស់ភាគីអាមេរិក ដាក់ការរឹតត្បឹតទិដ្ឋាការមកលើមន្ត្រីជាន់ខ្ពស់របស់ក្រសួងការបរទេស ក្នុងពេលដែលកម្ពុជាបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ លើបញ្ហានេះ។

ចំណែកកិច្ចសហប្រតិបត្តិការលើការស្វែងរកអដ្ឋិធាតុទាហ៊ានអាមេរិក **ឯកឧត្តមប្រធានគណៈប្រតិភូ** បានវាយតម្លៃខ្ពស់ និងបានសម្តែងកតញ្ញូតាធម៌ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អវិសេសវិសាលរបស់កម្ពុជាលើការងារនេះ ហើយបានគូសបញ្ជាក់ពីបំណងរបស់សហរដ្ឋអាមេរិក ក្នុងការបន្តកិច្ចសហប្រតិបត្តិការនេះឡើងវិញ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានលើកឡើងពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកកិច្ចសហប្រតិបត្តិការនេះជាបញ្ហាមនុស្សធម៌ និងបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ហើយក៏បានគូសបញ្ជាក់ពីការយកចិត្តទុកដាក់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** លើបញ្ហានេះ ដោយបានអន្តរាគមដោយផ្ទាល់ ក្នុងករណីដែលប្រតិបត្តិការនេះជួបឧបសគ្គ។ **ឯកឧត្តម** បានសង្កត់ធ្ងន់ថាការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្អាកជាបណ្តោះអាសន្ននូវកិច្ចសហប្រតិបត្តិការខាងលើ គឺជាការសម្រេចដើម្បីឆ្លើយតបទៅនឹងការសម្រេចពុំមានហេតុផលត្រឹមត្រូវ ក្នុងការដាក់ការរឹតត្បឹតទិដ្ឋាការមកលើមន្ត្រីជាន់ខ្ពស់របស់ក្រសួងការបរទេសកម្ពុជា។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការត្រៀមដំណើរការឡើងវិញនូវកិច្ចសហប្រតិបត្តិការភ្លាម បន្ទាប់ពីមានការសម្រេចដកការរឹតត្បឹតទិដ្ឋាការនេះ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសត្រង់ទៅត្រង់មក និងយោគយល់គ្នា។

ថ្ងៃ ពុធ ០៧ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៨